ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ២០៦ កសក

# សេចក្តីអំពាវនាវ

ក្នុងរដូវវស្សាឆ្នាំ ២០០៤ កន្លងមកនេះ ការងារបង្កបង្កើនផលស្រូវ ត្រូវជួបប្រទះនឹងគ្រោះរាំងស្ងួតជាបន្តបន្ទាប់ ពិសេសនៅចុងរដូវដែលគ្រោះរាំងស្ងួតនេះ កើតមានស្ទើរទូទាំងប្រទេសបង្កអោយមានការខូចខាតដំណាំស្រូវមួយចំនួន ទោះបីមានកិច្ចអន្តរាគមន៍សង្គ្រោះស្រូវយ៉ាងច្រើនពីបណ្តាអង្គភាព ស្ថាប័ននានា និងរាជរដ្ឋាភិបាលក៏ដោយ ។ ដោយឡែកនៅរដូវប្រមូលផលឆ្នាំនេះ ដោយភាពរាំងស្ងួតខ្លាំងនៅតាមខេត្តមួយចំនួននាពេលថ្មីៗក៏មានកើតបាតុភាពភ្លើងឆេះស្រូវអស់ជាច្រើនហិកតា បណ្តាលអោយមានការបាត់បង់ផលស្រូវអស់យ៉ាងច្រើនផងដែរ ។ លើសពីនេះទៀត ក៏នៅមានការនាំចេញស្រូវអង្ករដោយខុសច្បាប់ពីមូលដ្ឋាននានា តាមច្រករបៀងតូចធំដោយលួចលាក់ខុសច្បាប់ទៅកាន់ប្រទេសជិតខាងផ្សេងទៀត ទោះបីជាមានសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៣៧២ សជណ.សរ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០៤ កន្លងទៅហើយក៏ដោយ ។

យល់ឃើញពីផលវិបាកខាងលើ គួបផ្សំគ្រោះធម្មជាតិក្នុងតំបន់ដែលនឹងអាច បណ្តាលឱ្យមានការខ្វះខាតស្បៀងក្នុងឆ្នាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការអំពាវនាវដល់បងប្អូនប្រជាកសិករ ផ្នែកឯកជន និងអាជ្ញាធរដែនដីពាក់ព័ន្ធដូចខាងក្រោម:

១- សូមបងប្អូនប្រជាកសិករទាំងអស់មេត្តាទុកដាក់ផលស្រូវដែលប្រមូលរួចឱ្យបានគត់មត់ល្អ ចៀសវាងការប្រើប្រាស់ លក់ដូរខ្ជះខ្ជាយដែលអាចបណ្តាលអោយមានការខ្វះខាតស្បៀងអាហារប្រចាំគ្រួសារនៅពេលខាងមុខ ។

២- សូមឱ្យក្រុមហ៊ុន សហគ្រាស ពាណិជ្ជករដែលមានទុន ដោយរួមទាំងសមាគមម៉ាស៊ីនកិនស្រូវនានាផងដែររួតរះធ្វើការប្រមូលទិញផលស្រូវពីបងប្អូនប្រជាកសិករ តាមតម្លៃទីផ្សារសមស្របមកស្តុកបំរុងសំរាប់លក់ផ្គត់ផ្គង់ក្នុងស្រុកនៅពេលជួបប្រទះការខ្វះខាតស្បៀងអាហារនៅពេលខាងមុខ ។

ទង្វើនេះជាការរួមចំណែកជួយដោះស្រាយបញ្ហាចំពោះមុខរបស់ប្រទេសជាតិយើងយ៉ាងប្រសើរ ។

៣- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ខេត្ត-ក្រុង ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ដើម្បីចាត់វិធានការរាំងខ្ទប់ការនាំចេញស្រូវអង្ករដោយខុសច្បាប់ពីមូលដ្ឋាននានាតាមច្រករបៀងតូចធំទៅកាន់ប្រទេសជិតខាង ដែលនឹងបណ្តាលអោយកម្ពុជាកាន់តែជួបប្រទះនូវបញ្ហាខ្វះស្បៀងអាហារតទៅមុខទៀត ជាពិសេសឆ្នាំនេះ រាជរដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងលំបាកលំបិនណាស់ទំរាំឆ្លងផុតឧបសគ្គធំៗ ដើម្បីទទួលបានលទ្ធផលជាផ្លែផ្កានេះ ។

៤- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវលិខិតបទដ្ឋានដែលរាជរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញកន្លងមក ជាពិសេសសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៣៧២ សជណ.សរ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីករណីវិធានការឆ្លើយតប សង្គ្រោះបន្ទាន់ចំពោះគ្រោះរាំងស្ងួតនៅបណ្តាខេត្តមួយចំនួន និងសេចក្តីណែនាំ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ៤៣០ សរណន.កសក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីវិធានការការពារនិងទប់ស្កាត់ការបាត់បង់ផលស្រូវឆ្នាំ ២០០៤-២០០៥ ក្នុងពេលប្រមូលផល និងការរក្សាទឹកសំរាប់តម្រូវការជាសារធារណៈ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានក្តីសង្ឃឹមយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវរបស់បងប្អូនប្រជាកសិករ ផ្នែកឯកជន សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ក្នុងការរួមសហការអនុវត្តតាមសេចក្តីអំពាវនាវនេះ សំដៅធានាសុវត្ថិភាពស្បៀង និងសុខុមាលភាពជូនប្រជាពលរដ្ឋទាំងមូល ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០០៥

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ជ័ន្ទ.សារុន